ការសំភាសន៍របស់អ៊ុស្រី ហម ហ៊ុ

ក៖ អ្នកសំភាស៍គេឈ្មោះ សេង ផារីដា ខ៖ អ្នកគេត្រូវសំភាស៍ឈ្មោះ ហម ហ៊ុ

ក៖ និងហើយអ៊ុ ខ្ញុំឈ្មោះ ឈ្មោះពេញ សេង ផារីដា អ៊ុឈ្មោះអីគេដែរអ៊ុ? ឈ្មោះពេញ។
ខ៖ ខ្ញុំឈ្មោះ ហម ហ៊ុ ។
ក៖ ហម ហ៊ុ។
ខ៖ ចា!
ក៖ អឺ អ៊ុមានឈ្មោះហៅក្រៅអត់អ៊ុ?
ខ៖ អត់មាន អត់មាន។
ក៖ ឬក៏ឈ្មោះពីក្មេង?
ខ៖ ឈ្មោះតាំងពីកំណើត ម៉ែប៉ាដាក់អោយរហូតដល់ប៉ុណ្ណឹង។
ក៖ ពួកខ្ញុំមានnicknameរហូតពួកខ្ញុំ.អ៊ុមានអាយុប៉ុន្មានហើយឆ្នាំនឹង?
ខ៖ ខ្ញុំមានអាយុ ៦៦ឆ្នាំ។
ក៖ ៦៦ អ៊ុកើតនៅឆ្នាំណារិញ?
ខ៖ ដូចជា១៩៥២។
ក៖ ១៩៥២ អ៊ុចុះឆ្នាំចន្ទគតិ?
ខ៖ ឆ្នាំខែតើហី?
ក៖ ឆ្នាំ ដូចជាឆ្នាំកុរឆ្នាំឆ្លូរឬក៏ឆ្នាំអ្វីចឹង។
ខ៖ អូ ឆ្នាំម្សាញ់។
ក៖ ឆ្នាំម្សាញ់មាន់ហីអ៊ុ?
ខ៖ ពស់ រកាបានមាន់។
ក៖ អត់ច្បាស់ដែររឿងឆ្នាំខ្មែរ ហិហិ។
ខ៖ និងហើយៗ។
ក៖ អឺ អ៊ុកើតនៅណាដែរនៅពេទ្យ នៅផ្ទះ ....។
ខ៖ អត់ទេ កើតនៅតាមជារបៀបអ្នកស្រែកើតនៅយាយមបខ្មែរយើង
នៅស្រុកស្រែជនបទនៅភូមិច្រាំងក្រហម។
ក៖ កើតនៅច្រាំងក្រហមភូមិឃុំណាដែរអ៊ុ ?
ខ៖ ភូមិឃុំសង្កាត់កំពង់ស្វាយស្រុកកំពង់ស្វាយដែរ។
ក៖ ភូមិច្រាំងក្រហម។
ខ៖ ភូមិច្រាំក្រហមឃុំកំពង់ស្វាយ។
ក៖ ឃុំកំពង់ស្វាយ។
ខ៖ ឃុំ អូ សង្កាត់កំពង់ស្វាយពីមុនន+ក្រឹន។
ក្រឹន៖ ជាទនៅនិងដែរតើ។
ខ៖ កាលយើងនៅច្រាំងក្រហម.ក្រឹន. ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ។
ក៖ និងហើយ ផ្លាប់លីឈ្មោះនិងដែរតើ ភូមិនិងដូចជាភូមិដីក្រហមមែនអ៊ុ។
ក្រឹន៖ មិនមែនទេ។
ខ៖ អត់ទេ..។
ក៖ ផ្លាប់ស្គាល់អ៊ុនៅច្រាំងក្រហមដែរ គាត់ហៅទៅលេង អត់ដែរជានទៅ។
ខ៖ និងហើយ។
ក៖ អ៊ុមានបងប្អូនប៉ុន្មានអ្នកដែរអ៊ុ?
ខ៖ ខ្ញុំមានបងប្អូន៥នាក់ស្រី២ប្រុស៣។
ក៖ អ៊ុ អ៊ុកូនទីប៉ុន្មានដែរអ៊ុ?
ខ៖ ខ្ញុំដូចកូនទី២។
ក៖ កូនទី២.ក្រឹន. ដូចទៀត ហិហិ។
ក៖ បងប្អូនអ៊ុមានឈ្មោះអ្វីខ្លះដែរអ៊ុ?
ខ៖ បងប្អូនខ្ញុំ បងប្រុសឈ្មោះញឹម ហមញឹប ហើយទៅខ្ញុំហមហ៊ុ
ប្អូនប្រុស១ទៀតហម ហុង ១ទៀតហមពៅ។

កះ ចាស អ៊ុំមានចាំរឿងអ្វីខ្លះដែរអំពីពួកគាត់ដែរអត់អ៊ុ?
ខះ អំពីពួកបងប្អូន ?
កះ និងហើយៗ អ៊ុំពីបងប្អូនអ៊ុ។
ខះ ហឹម មិនសូវចាំអីពីប៉ុន្មានទេ
ប៉ុន្តែបងប្អូនខ្ញុំដូចជាមិនល្អហើយក៏មិនជាអាក្រក់អីដែរ
ធ្វើអោយក្រុមគ្រួសារពិបាក។
កះ និងហើយ..!
ខះ គ្រាន់តែចាំប៉ុណ្ណឹង។
កះ ចាំរឿងលេងមួយគ្នាឬក៏អី...។
ខះ អូ អត់ទេ អត់ដែរទេ អត់ដែរលេងមួយគ្នា មានប្តីប្រពន្ធមួយគ្នាសហូរហែរ អូ
មានប្អូន១ប្អូនទី៤ មួយគេលេងប្រពន្ធតែគេមានគ្រួសារថ្មីទៀតហើយ។
កះ អឺ នៅអ៊ុំនៅពីក្មេង អ៊ុំចូលចិត្តធ្វើអ្វីខ្លះដែរអ៊ុំពីតូច?
ខះ គឺខ្ញុំមិននេះទេ
ខ្ញុំនៅពីក្មេងៗពួកខ្ញុំអ្នកធ្វើស្រែចំការនាំគ្នាទៅស្រែទៅអីនុងអែង។
កះ ទៅស្រែជាមួយគ្នាជាមួយបងប្អូន។
ខះ និងហើយជាមួយបងប្អូននិង។
កះ ចុះអាឡរគាត់រស់នៅណាខ្លះដែរអ៊ុ។
ខះ សព្វថ្ងៃបងប្រុសខ្ញុំមួយដែរឈ្មោះ ហមហ៊ុ និងនៅអីជ្រាំងក្រហមនិងអែង។
កះ ជ្រាំងក្រហមនឹងដែរ។
ខះ និងហើយ តែ៤នាក់និងបានមកដល់កំពង់ធំហើយ។
កះ អាឡរគាត់។
ខះ មកនៅនិងខេត្តនិង។
កះ នៅទីតួមខេត្ត។
កះ នៅទីរួមខេត្តទាំងអស់មែន?
ខះ និងហើយ។
កះ នៅជិតៗអ៊ុតើហី?
ខះ និងហើយនៅជិតដូចផ្ទះខ្ញុំនិងផ្ទះប្អូនខ្ញុំប្រុសមួយផ្ទះនៅទល់មុខគ្នាប្អូនទី៤។
កះ និងហើយ!
ខះ បើប្អូនប្រុស១នោះនៅអីជិតស្ពានតូងចាមទល់មុខ
ម្តុំអេស៊ីលីដាប៉ុននៅខាងនេះ។
កះ ចុះអាឡរគាត់ធ្វើអ្វីខ្លះដែរអ៊ុ ការងារពួកគាត់។
ខះ បើបងប្រុសខ្ញុំនិយាយពីលើមកមុនកុំអោយនិយាយបញ្ហាស។
កះ និងហើយ ហិហិ អ្វីក៏បាន។
ខះ បងប្រុសខ្ញុំគាត់ធ្វើស្រែហើយតែខ្ញុំ
ខ្ញុំអស់អីធ្វើហើយពីដើមធ្វើស្រែតែអាឡរអោយកូនក្មួយធ្វើទៅ។
កះ ចា!
ខះ
ហើយប្អូនប្រសខ្ញុំទី៣គេលក់គ្រឿងអីក្របិចក្របុកហើយម៉ាស៊ីនដេរម៉ាស៊ីនអីនុង
ហាស។
កះ ចាស.!
ខះ ហើយរកអីចឹងអែង លក់ហ្គាសលក់អីហ្គាសសប់ហ្គាសអី។
កះ ហ្គាសកំប៉ុង ។
ខះ អត់ទេ អាហ្គាសសប់ ហ្គាសគេបូមខ្យល់។
កះ អូ..!
ខះ ហ្គាសគេបូមខ្យល់ អាហ្គាសសប់រែងៗវាលក់សំភារគ្រឿងនោះអែង
ហើយទៅប្អូនប្រុសនោះប្អូនប្រុសទី៣ ប្អូនប្រុសទី៤នុងដូចជាអត់មានធ្វើអីទេ
សព្វថ្ងៃធ្វើតែស្រែដែរ។

កះ ចាស..!
ខះ មកនៅកំពង់ធំក៏ទិញដីគេបានប្រហែលជា អឺ
ថារាអត់ដល់១ហិចទេដីនុងនោះវាស្មើរ១ហិចទៅចុះព្រោះអា១នោះ៤៥អាមួយនោះ
១៦ ប៉ុនយើងគិតថា១ហិចចុះ ១ហិចនុងគ្នាធ្វើស្រែនុងអែង
ពីដើមចិញ្ចឹមគោចិញ្ចឹមអីដល់កម្លាំងចាស់ទៅរាវត់អត់រួចក៏លក់គោចោលអស់ធ្វើ
តារ៉ែស។
កះ និងហើយ។
ខះ ហើយប្អូនស្រីខ្ញុំនិងធ្វើការកំបិចកំប៉ុកនុងអែងចេះតាដាំបន្តែ
ដាំដីអីលក់គ្រាន់ចិញ្ចឹមកូនរៀន។
កះ ចុះ អីម្តាយអ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?
ខះ ម្តាយខ្ញុំឈ្មោះហង្សយៀន។
កះ ចុះឪពុកអ៊ុំ?
ខះ ឪពុកខ្ញុំឈ្មោះសៀវហម។
កះ អាឡូវគាត់ចែកឋានទៅអ៊ុំ?
ខះ និងហើយ គាត់ស្លាប់អស់ហើយ។
កះ និងហើយ ..។
ខះ គាត់បានអាយុ៧០ជាង ប៉ុណ្ណឹងទៅអស់ហើយទៅ។
កះ គាត់កើតនៅណាដែរអ៊ុំស្រុកកំណើតរបស់ឪពុកម្តាយអ៊ុំ?
ខះ ឪពុកម្តាយខ្ញុំ ម្តាយខ្ញុំកើតនៅច្រាំងក្រហមនឹងអែង។
កះ អ្នកច្រាំងក្រហម ហិហិ។
ខះ តែឪពុកខ្ញុំនៅម្តុំ បើនិយាយទៅនៅខ្សាច់ចង្អេរនៅកំពង់គោ។
កះ កំពង់គោ។
ខះ និងហើយស្រុកកំណើត។
កះ អ៊ុំអ្នកកំពង់ធំសុទ្ធម៉ងផង។
ខះ ចា កំពង់ធំសុទ្ធ គាត់នៅខ្សាច់ចង្អេរបើតាមដែលខ្ញុំដឹងថា
ដូនតាខ្ញុំគាត់នៅនោះអែង។
កះ ចា ចុះនៅពេលដែរគាត់ឪពុកអ៊ុំ គាត់អីគេ
ដូចជាដើម្បីចិញ្ចឹមជីវិតរបស់គាត់ដែរអ៊ុំ?
ខះ ចា ម៉ោដល់និងក៏គាត់បានប្តីប្រពន្ធទៅក៏គាត់បែកពីម្តាយឪពុកគាត់ម៉ោ
គាត់ម៉ោនៅខាងម៉ែខ្ញុំ គាត់ធ្វើស្រែដែរ ។
កះ ចុះអ៊ុំ ឪពុកម្តាយអ៊ុំមានផ្តាប់ប្រាប់អ៊ុំពីជីវិតគាត់កាលពីនៅក្មេងដែរអត់អ៊ុំ?
ខះ គាត់អត់សូវបាននិយាយទេប៉ុន្តែ
បើម្តាយខ្ញុំគាត់បាននិយាយដែរគាត់កំសត់ណាស់ព្រោះគាត់អត់មានឪពុកម្តាយ
ចិញ្ចឹមតាំងពីតូចៗម៉ោ គាត់ស្លាប់ចោលអស់មក ។
កះ ចា។
ខះ
ម្តាយគាត់ដូចជាទាស់ត្រីក្រាយដែរចាស់ៗពីដើមគាត់អត់បានយកមកពេទ្យអី
យកមកអីមើលត្រឹមត្រូវទៅក៏គាត់ស្លាប់ គាត់មានប្អូនស្រី១
ប្អូនស្រីមួយនោះក្រោយពីអត់ម្តាយទៅក៏ស្លាប់ដែរ។
កះ អូ.!
ខះ នៅសល់តែគាត់ម្នាក់។
កះ ចឹងបងប្អូនមានគា២នាក់បងប្អូន
ហើយប្អូនគាត់ស្លាប់ចឹងម្តាយអ៊ុំម្នាក់អែង។
ខះ ចា និងហើយ មានតាម្នាក់គាត់?
កះ កាលនិងគាត់ដូចជានៅតូចដែរន៎អ៊ុំ។

ខ៖ នៅតូច ប្រហែលជានៅតូច ព្រោះលីគាត់ថា
ពេលឪពុកគាត់ទៅចង់សន្លូចទៅរកត្រីអីយប់ៗដាក់គាត់ក្នុងហិបកុំអោយមុសខាំ
កូន។
ក៖ អូ ហិហិ។
ខ៖ ដេកចូលក្នុងហិប។
ក៖ ជំនាន់និងអត់ទាន់មានមុង។
ខ៖ និងហើយអត់ទាន់មានមុង ប្រហែលនិងអែង។
ក៖ អត់ហប់ទៀតន ហិហិ។
ខ៖ និងហើយ គាត់ថាគាត់ដេកក្នុងហិប។
ក៖ អូ.!
ខ៖ ឪពុកមករិញក់លើកកូនចេញពីហិបដាក់អោយដេក
ប្រហែលជាអត់មុងនិងអែងកូនចាស់ៗពីមុន។
ក៖ និង បើគិតពីរាប់ជំនាន់គាត់មកយើងចូល៩០តែ៩០ស្តើង។
ខ៖ ចូល៨០,៩០ហើយ និងហើយ គារដូចកើត១៩២០ជាង។
ក៖ អូ ពីជំនាន់២០ជាងដូចជាជំនាន់សម្តេចសីហនុ។
ខ៖ និងហើយជំនាន់គាត់និងអែង។
ក៖ និងហើយ។
ខ៖ ជំទាន់សម្តេចសីហនុអីនុង អោយធ្វើកាំភ្លើងឈើអី។
ក៖ ចុះអ៊ុំមាននៅចាំឈ្មោះជីដូនជីតាអ៊ុំដែរទេ
ខាងម្តាយក៏បានខាងឪពុកក៏បាន។
ខ៖ ជីដូនជីតាខាងឪពុក ប៉ាខ្ញុំឈ្មោះម៉ារេ
កុងខ្ញុំឈ្មោះស៊ីរតែអត់ស្គាល់ឪពុកកុងនិងទៀតទេអត់កើតអត់ទាន់។
ក៖ អត់អីទេ គ្រាន់តាចង់ដឹងឈ្មោះ តាយាយយើង។
ខ៖ ចាស និងហើយ តានិងឈ្មោះកុងស៊ីរ។
ក៖ គាត់នៅខាងឪពុកហអ៊ុំ។
ខ៖ ចា ខាងប៉ាខ្ញុំ។
ក៖ និងហើយ ចុះហ៎។
ខ៖ ម៉ានិងឈ្មោះម៉ារេ។
ក៖ ចា!
ខ៖ និងអែង។
ក៖ ចុះអ៊ុំចាំថាគាត់កើតក្នុងឆ្នាំណាហើយនៅណាអត់អ៊ុំ។
ខ៖ អត់បានទេ។
ក៖ ឬក៏អី។
ខ៖ អាយុគាត់ដូចជា៨០អីជាងគាត់ស្លាប់ចើម៉ានោះគាត់ស្លាប់សម័យលន់នល់។
ក៖ ចា!
ខ៖ ដឹងគាត់អាយុបានប៉ុន្មានខ្ញុំអត់ដឹងទេ
ប៉ុនខ្ញុំតែងលឺប៉ាថាកុងខ្ញុំបានអាយុ៨៩បានគាត់ស្លាប់។
ក៖ ចុះអ៊ុំធ្លាប់ចាំរឿងអំពីពួកគាត់អត់អ៊ុំ។
ខ៖ អត់!
ក៖ ដោយសារនៅក្មេងដែរពិបាក ហិហិ។
ខ៖ បើដឹង ដឹងពីតូចថា របរម៉ាកុងខ្ញុំគឺដាំអំពៅ
ដាំតាអំពៅទេនៅស្រុកនិងនោះហើយធ្វើស្រែ។
ក៖ នៅស្រុកណាដែរអ៊ុំ។
ខ៖ នៅ នៅខ្សាច់ចង្អួសនិងអែង។
ក៖ អូ ដាំអំពៅនៅនិងដាំអំពៅកើត។
ខ៖ ដាំអំពៅនៅនិងគេដាំអំពៅកើតកូន។
ក៖ ចា!

ខ៖ សម័យនោះ ខ្ញុំទៅជួបកាលជាខ្ញុំនាំទៅលេងអី
ឃើចំការអំពៅគាត់ធំហារណាស់គាត់ដាំ។
ក៖ និងហើយ។
ខ៖ ជើញចឹងអែងហើយនិងធ្វើស្រែនិងអែង។
ក៖ ចា ចុះក្រុមគ្រួសាររបស់អ៊ុំនោខេត្តនិងអស់យូរប៉ុនណាហើយដែរអ៊ុំ។
ខ៖ នៅខេត្តកំពង់ធំយើងនិងហ៎ ។
ក៖ និងហើយ យូរហើយមែនអ៊ុំ។
ខ៖
យូរហើយអត់ដែរផ្លាស់ប្តូរទៅណាទេទើបសម័យអាពាតទេដែរអ៊ុំបែកទៅនៅកំពង់ចាម ?
ក៖ ចា.!
ខ៖ ក្តងចំការកៅស៊ូ។
ក៖ អូ កំពង់ចាមចំការកៅស៊ូ។
ខ៖ ចា!
ក៖ អឺ អ៊ុំមានសាច់ញាតិណាដែរនៅក្រៅពីប្រទេសកម្ពុជាដែរទេ។
ខ៖ អត់ អត់មានទេ។
ក៖ អត់មាន។
ខ៖ អត់មានសោះ។
ក៖ ចុះស្វាមីរបស់អ៊ុំឈ្មោះអ្វីដែរអ៊ុំ។
ខ៖ ប្តីខ្ញុំឈ្មោះ អានឈុនអ៊ុំ។
ក៖ អានឈុនអ៊ុំ ស្រដៀងម្នាក់ខ្ញុំស្គាល់ឈ្មោះសមាជិកវិហារដែរឈ្មោះអ៊ុំមឈុនអ៊ុំ ហិហិ។
ខ៖ ចា!
ក៖ អ៊ុំរៀបអាពាហ៍ពិពាហ៍នៅឆ្នាំណាដែរអ៊ុំ។
ខ៖ ខ្ញុំរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ៧០ ឆ្នាំ១៩៧០។
ក៖ នៅឆ្នាំ១៩៧០ ចុះនៅថ្ងៃខែណាដែរអ៊ុំ អានុងដូចេជារបបលន់នល់១៩៧០។
ខ៖ របបលន់នល់១៩៧០ រៀបការនៅខែ៤។
ក៖ ខែ៤។
ខ៖ និងហើយ ឆ្នាំ១៩៧០
បើគិតជាខែខ្មែរយើងខែចេត្រព្រោះខ្ញុំការហើយខ្ញុំចូលឆ្នាំ។
ក៖ អូ តែអាការនិងរៀបចំពីឪពុកម្តាយឬក៏ម៉េចអ៊ុំ។
ខ៖ រៀបចំពីឪពុកម្តាយ។
ក៖ ខ្ញុំស្តានតាមកពីអាស្អីគេ អាស្អីគេអង្ការគេនោះ។
ខ៖ អត់ទេ អត់មានអង្ការរៀបចំអីទេឪពុកម្តាយទាំងសងខាង។
ក៖ ចា ចុះមានផ្លែដំនូនដែរអត់អ៊ុំ?
ខ៖ មានដំនូនកាលនឹងគេជូនពាន់។
ក៖ ច្រើនហារ។
ខ៖ ពាន់ខ្មែរពីដំណាន់និង និងហើយ ពាន់បើគិតជាមាស១តម្លឹងជាង។
ក៖ ច្រើនហារដំនាន់នោះ។
ខ៖ ច្រើនសម័យនិង១ជីតា២រយ។
ក៖ អាឡវម៉ានរយដែរតែរយដុល្លា។
ខ៖ និងហើយរយដុល្លា ស្រួលរកមិនបានទិញមាសទេអាឡវ។
ក៖ ចា ស្រួលមិនស្រួលស្តានលុយទិញមាសទេ។
ក៖ តើអ៊ុំអាចប្រាប់ពួកខ្ញុំបានទេពីដំបូងដែរអ៊ុំហើយនិងស្វាមីអ៊ុំជួបគ្នា។
ខ៖ បើនិយាយទៅប្រហែលកូនអែងអត់ជឿ អ៊ុំអត់ដែរស្គាល់គ្នាសោះ។
ក្រឿនះ និយាយតាំងពីព្រេងនាយសំបើមម្ល៉ះ។
ក៖ អត់ទេ ដូចជាគេសួរទាក់ទងនិង។

ខ៖ ដំបូងស្គាល់ឪពុកម្តាយព្រោះភូមិជ្រាំងក្រហមនិងតាប៉ោងវាជាប់គ្នា។
ក៖ តាប៉ោងនិងជ្រាំងក្រហម អូ ហិហិ។
ខ៖ ១នៅភ្នំពេញ ប្តីខ្ញុំគាត់នៅភ្នំពេញស៊ីឈ្នួលគេ។
ក៖ អូ ឪពុកម្តាគាត់នៅខេត្តគាត់នៅភ្នំពេញ។
ខ៖ ម្តាយនៅស្រុកតាប៉ោង។
ក៖ នៅជាប់គ្នាគ្រាន់តាគាត់នៅផ្សេងពីឪពុកម្តាយ។
ខ៖ ចា ដល់ពេលរួចទៅក៏ឪពុកម្តាយទាំងសងខាងនិងស្គាល់គ្នា ចាស់ៗនិង។
ក្រឿង៖ ចុះពីដើមមិនដូចក្មេងសម័យអាឡូវណា។
ខ៖ អរដែរស្គាល់គ្នាសោះកូនពេលគេហែរកូនប្រុសមកចូលរោងរត់ទៅមើល។
ក៖ អើរ ការបណ្តោយអ៊ុំ។
ខ៖ និងហើយ មែនតើ អត់ដែរស្គាល់គ្នាទេមិនដែរសោះប៉ុននឹកឃើញថា
ប៉ាម៉ែគេស្អាតហេតុអីកូនគេមិនស្អាត។
ក៖ ដល់ពេលជួបស្អាតមែន។
ខ៖ ដល់ពេលជួបស្អាតមែនឪវាស្អាត គាត់ជាមនុស្សមិននេះទេ គាត់មឹងមាត់
គាត់អត់ចេះផឹកស៊ីល្បែងស្រីញីអីទេ។
ក៖ ចុះអ៊ុំមានចេះ អូច្រលំ
អ៊ុំមានចេះអាននិងសរសេរភាសាខ្មែរបានច្រើនប៉ុនណាដែរអ៊ុំ?
ខ៖ ជាភាសាខ្មែរអ៊ុំមិនចេះអីជ្រៅជ្រះទេ។
ក៖ ទេ ជាទូទៅម៉ាប្រើបានធម្មតា។
ខ៖ អាចប្រើបានធម្មតា សរសេរសំបុត្រអីនិង។
ក៖ និងហើយ..។
ខ៖ ប្រើបានធម្មតា។
ក៖ ចុះអ៊ុំមានចេះភាសាអីដែរក្រៅពីភាសាខ្មែរដែរទេ?
ខ៖ អត់ អត់ចេះសោះ។
ក្រឿន៖ ចេះតាភាសាខ្មែរច្បាស់ម៉ង។
ក៖ និងហើយ។
ខ៖ ព្រោះអត់ដែរបានរៀន។
ក្រឿន ម៉ាជំនាន់និងរៀនស្លឹ។
ខ៖ រៀនបានដូចខ្ញុំថានិងអែង ថ្នាក់ទី១០។
ក៖ ចឹងតើអ៊ុំរៀនបានកម្រិតថ្នាក់ទីប៉ុន្មាន បឋម
មធ្យមសិក្សាឬក៏ទុតិយភូមិឬអីផ្សេងៗ?
ខ៖ អត់មានបានអីទេ។
ក៖ និងអ៊ុំប្រាប់ខ្ញុំមុននិងតែសំណួរគេត្រូវសួរ។
ខ៖ និងហើយ។
ក្រឿន៖ បើនិយាយចំទៅវាលើសថ្នាក់អង់តាងតែមួយថ្នាក់និង។
ខ៖ និងបានថាសព្វថ្ងៃគេរៀនលើថ្នាក់ទី៣ ទី១២ ១១។
ក៖ ជំនាន់និងគេកម្រឹតអីវិញអ៊ុកម្រឹតអ៊ុចូលរៀន?
ក្រឿន៖ ទេជំនាន់និងមិនមែនកម្រឹត១ទេ គេមិនមែនហៅចឹងទេ។
ខ៖ ពីមុនគេហៅកុមារហាន។
ក៖ កុមារហាន។
ខ៖ និងហើយ ប្រហែលដូចជាថ្នាក់ទី១០ វា៣ថ្នាក់ទី១២ ១១។
ក្រឿន៖ មិនបាច់និយាយចឹងទេ ថារៀនបានតា៣ថ្នាក់ចឹងទៅ
ខ៖ រៀនបានថ្នាក់ទី១០ អាឡូវគេរាប់ពី១ ២ ឡើងទៅទី១២វិញ
សម័យមុនពីទី១២ចុះមកក្រោមវិញ។
ក៖ អូ!

ខ៖
ជាក់ឌុបនិងគេហៅថ្នាក់ទី១ទំនើបរបស់គេអត់មែនហៅដូចអាឡរពីទី១ទៅទី១២
ទេពីមុនវិញថ្នាក់ជាក់ឌុបទី១បស់គេហើយដល់អាឡរគេដូរ។
ក្រឿន៖ មិនចាំជាច់តែជាក់ឌុបទេ តែឱប្លួមក្មេងសព្វថ្ងៃមិនជាច់លោតទេ។
ក៖ ក្មេងអាឡរទី៧។
ក្រឿន៖ ឱប្លួមទី៩។
ក៖ ទី៩និងហើយ ចឹងអ៊ុំរៀនជានកម្រឹតទី៣ណេសអ៊ុំ។
ខ៖ និងហើយកម្រឹតទី៣។
ក្រឿន៖ និងហើយកម្រឹតទី៣។
ក៖ និងខ្ញុំអត់សូរដឹងពីថ្នាក់ពីមុនបើសួរពីបឋមអនុអីដឹង។
ខ៖ អ៊ុចាំតាអទឹកហានអាមួយទៀតនោះដឹងថ្នាក់អី។
ក៖ និងហើយដោយសារយូរដែរហើយ។
ខ៖ និងហើយៗប្រហែលជាបវេចនហាននិងអែង.។
ក៖ សាលាអ៊ុំរៀននៅណាដែរអ៊ុំ ?
ខ៖ នៅសាលាតាប៉ោង។
ក៖ តាប៉ោង។
ខ៖ និងហើយ។
ក៖ អ៊ុំមានចាំឈ្មោះសាលានិងឈ្មោះអីដែរអ៊ុំ?
ខ៖ សាលានិងប្រហែលគេដាក់ឈ្មោះសាលាវត្តកោះរកា។
ក៖ កោះរកា និងហើយអត់អីទេអ៊ុំ សំនួរខ្លះ។
ខ៖ តាមដឹង អត់មានណាជួយទេ លោកអ្នកកសាងឡើង?
ក៖ និងហើយគ្រាន់ជាសំនួរ។
ក្រឿន៖ ហែងនិយាយភាសានិង លោកអ្នកកសាងនិងអត់ដាក់ឈ្មោះទេ។
ខ៖ អត់ទេ ដូចជាដាក់ឈ្មោះកោះរកានិងអែង។
ក្រឿន៖ មិនមែនបឋម ដូចជាបឋមនិងអែង។
ខ៖ បើថ្នាក់បឋម កុមារហាននិងអែង។
ក៖ ចាស និងហើយ។
ក្រឿន៖ ទេជំនាន់នោះដូចជាមែនបឋម
កាលនោះដូចជាភ្លេចអស់ជាត់ទៅហើយ។
ខ៖ អានិងហៅថ្នាក់កុមារហាននិងអែង។
ក៖ ហិហិហិ។
ខ៖ កុមារហាន អតិកហានបរិវេចនហាននិងអែង។
ក្រឿន៖ កាលនិងមែនភាសាបាលីទេ សាលារដ្ឋណាគេដាក់ចឹង។
ខ៖ មិនដឹងដែរ។
ក៖ និងហើយ
ចឹងអ៊ុំមានមិត្តជិតស្និតណាដែរធំធាត់ជាមួយគ្នាតាំងពីដល់ឥឡូវទេអ៊ុំ?
ខ៖ តាំងពីក្មេងមកខ្ញុំមិនដែរមានមិត្តភក្តីជិតស្និតអីទេ
គ្រាន់ថាពួកដែររៀនជាមួយគ្នាកាលនៅវត្តនៅសាលាក៏នៅតែរាប់អានគ្នាស្និតស្នាល តែអ្នកខ្លះក៏ស្លាប់ខ្លះក៏នៅរស់។
ក្រឿន៖ ចុះបើសុទ្ធតែ៦០ ៧០។
ក៖ ហិហិហិ ចុះអ្នក។
ខ៖ ពេលជួបជុំគ្នាយើងក៏នៅតែរាប់អានគ្នាស្និតស្នាល។
ក៖ ចុះអ្នកដែរនៅរៀនស្គាល់គ្នាតាំងពីតូចដល់ឥឡូវ តាត់មានឈ្មោះអ្វីដែរ
អ្នកដែរអ៊ុំចាំបានចឹង។
ខ៖ ឈ្មោះហុង។
ក្រឿន៖ ណាចាំតាំងពីជំនាន់៧០មកហើយ។
ខ៖ និងហើយ ឈ្មោះសាត មីងសាតតាប្រិញហូត។

កះ ចា!
ខះ តាម៉ែងហើយហុងអីស្លាប់អស់ហើយ នៅហូតឬនហុងស្លាប់ហើយ។
កះ ចា!
ខះ ហើយប្រុសៗនិងខ្លះក៍ស្លាប់ខ្លះក៍បាត់មិនដឹងទៅណាទេ
ខ្លះក៍រៀនទៅគេចសាលាគេចអីទៅអត់រៀន។
កះ ចាស ចុះអ៊ុំមានចាំអីខ្លះដែរទាក់ទងនិងពួកគាត់ដែរអត់អ៊ុំ?
ខះ តាំពីបែកគ្នាបានប្តីបានអីទៅខ្ញុំដូចជាមិនសូវចាំរឿងរបស់គេទេកូន។
កះ និងហើយ ។
ខះ និងហើយ។
កះ ពេលខ្លះ អ្នកអ៊ុំស្គាល់ថា ពីមុគាត់ដូចជាខូចម៉េច។
ខះ ក្មេងសម័យមុនជាមនុស្សមិនសូវខិលខូចអីទេ ក្រឹមត្រូវជាងសម័យនេះ។
កះ ជំនាន់នោះអត់សូវ។
ខះ ជំនាន់នោះអត់មានគ្រឿនញៀនគ្រឿងអី
លេងតែលោតអន្ទក់លោតអីគ្មានលេងល្បែងស៊ីសងអីទេ ជះគ្រាប់អំពិល
ផ្តាត់កៅស៊ូ
កះ លេងអីៗមួយគ្នាចឹង។
ខះ និងហើយ លេងៗចឹងៗអែង។
កះ និងហើយ។
ខះ ល្បែងស៊ីសងខឹលខូចអីអត់មានទេសម័យនិងបើថា។
គ្រឿនៈ ចាប់ពីបិណ្ឌ១លោកដាក់បាស់ រាំទល់ភ្លឺ សម័យនេះមើលវាយគ្នាខ្ជិចឥឡូវ។
កះ មិនទាន់ចាក់បាសបានម៉ានបទផងវាយគ្នាបាត់
ចុះអ៊ុំធ្វើការស្រែឬប្រកបអាជីវកម្មគ្រួសារដែរអ៊ុំ។
គ្រឿនៈ កសិករ។
ខះ កសិករ គិតទៅរាល់ថ្ងៃអ៊ុំគ្មានធ្វើអីទេ អ៊ុំគ្រាន់ថាខែគេព្រោះសូវ ដើរទិញកាជិប
កាចៅអី ទិញល្ង ខែត្រីឆ្អើ ទិញត្រីឆ្អើយកទៅលក់បានចំនិញតិចៗគ្រាន់។
កះ អឺ ក្នុងនេះដូចជាគេសួរថា
តើអ៊ុំបានធ្វើការអីខ្លះទៀតក្នុងជីវិតអ៊ុំក្រៅពីការងារស្រែចំការ។
ខះ អ៊ុំអត់មានធ្វើអីទេ អត់មានទេ អ៊ុំអត់មានសោះ ការងាររដ្ឋសុីប្រាក់ខែប្រាក់អី
អតដែរបានទទួលទេ យើងអត់ដែរបានរៀនចេះដឹងហើយ អត់សូវហ៊ានទេ។
កះ ចា!
ខះ យើងក៍គ្មានខ្សែរយៈ និងហើយ។
កះ ចា ចុះតាំងពីក្មេងដល់ឥឡូវ តើជីវិតអ៊ុំមានការផ្លាស់ប្តូរអ្វីខ្លះដែរអ៊ុំ?
ខះ តាំងពីក្មេងមកដល់ចាស់សព្វថ្ងៃខ្ញុំដូចជាមានជីវិតផ្លាស់ប្តូរដែរ។
គ្រឿនៈ សំភាសន៍ដូចVOAហើយ។
កះ អត់ទេ គ្រាន់តែសំភាសន៍ជីវប្រវត្តិគាត់។
គ្រឿនៈ និងVOA។
ខះ តាំងពីមានក្រុមគ្រួសារមកខ្ញុំក៍ទទួលបានដូចថា
វាក៍បានកូន៥នាក់ខ្ញុំក៍បែកគ្នា គាត់ក៍ទៅបាត់
ខ្ញុំក៍នៅចិញ្ចឹមកូនទាំង៥និងអែង
រួចទៅក្រោយមកក៍បានដំណឹងល្អរបស់ព្រះយេស៊ូមកផ្សព្វផ្សាយខ្ញុំក៍បានទទួលដំ
ណឹងល្អពីព្រះមានតែប៉ុននឹងអែងកូន។
កះ និងហើយ។
ខះ ហើយក៍អរគុណព្រះដែរ
ដែរបានរើសខ្ញុំចេញពីអំពើបាបហើយពួកក្រុមគ្រួសារខ្មែក៍មានសុភមង្គលដែរ
មិនជាអាក្រក់ហើយក៍មិនជាល្អដែរវាមិនមែនថាវាល្អទាំងអស់ទេកូន
ប៉ុន្តែកូនចៅក៍ធ្វើអោយសប្បាយចិត្តដែរ
រាល់ថ្ងៃកូនក៍មិនដឹកស៊ីល្បែងស្រីក្លឹងដែរធ្វើអោយយើងពិបាកដែរណាស។

កះ ចាសនិយាយរួមទៅធម្មតា។
ខះ ចឹងអែង ចាសវារស់បានម៉ាស្រួល
និយាយរួមទៅវាក៏មានផ្ទះសំបែងរស់នៅសមរម្យរបស់គេហើយ
ហើយក៏ដូចថា ពួកគេដឹងគុណយើងដែរ គេមិនធ្វេសប្រហែសអារឿងអីទេ
គុណអាណនវាទៅតាមបែបបទនិងតគ្នាផង។
កះ និងហើយអ៊ុ ព្រោះធម្មតាឪពុកម្តាល្អគាត់ដូចជាដឹងគុណដឹងអីចឹង។
ខះ និងហើយ។
កះ ចុះអ៊ុំមានម្ហូបឬល្បែងណាដែរអ៊ុំចូលចិត្តតាំងពីក្មេងដល់ឥឡូវទេអ៊ុំ។
ខះ បើល្បែងលេងអី។
កះ ម្ហូបក៏បានល្បែងក៏បាន។
ក្រឿនះ បើនិយាយទៅ គាត់ចូលចិត្តប្រលោមលោកពីដើម។
ខះ និងហើយចូលចិត្តស្តាប់វិទ្យុចម្រៀងអីៗពិរោះៗដល់សព្វថ្ងៃ។
កះ តាំងពីដើម ។
ខះ មានទូរសព្ទដាក់ចម្រៀងអើយយើងស្តាប់កូនៗ បើនិយាយពីនេះ
ខ្ញុំចូលចិត្តស្តាប់ព្រះបន្លួល និកាយផ្សេងម៉េចមិនដឹងទេណាស ប៉ុនខ្ញុំគ្រាន់ថា
ម៉ោង៦ជាងអីខ្ញុំស្តាប់ព្រះបន្លួលដែរគេនិយាយតាមវិទ្យុ។
ក្រឿនះ ស្តាប់យើងចែកពេលម៉ោងមិនមែនស្តាប់ទាំងអស់ទេ។
ខះ
ដូនកាលនិកាយយើងអត់បានបំបែកអោយយើងយល់ពីពាក្យប្រៀបធៀបក្នុងគម្ពីរទេ និងហើយ ដល់ពេលនេះទៅ
ខ្ញុំបានស្តាប់ពួកគេនិយាយទៅបានយើងគ្រាន់យល់ខ្លះអំពីពាក់ប្រៀបធៀបនៅពេលយើងអានគម្ពីរទៅ
គិតវាអត់ដល់យើងអត់ដឹងថាគេប្រើទៅលើស្អីខ្លះយើងអត់ដឹងអត់យល់ណាស់ហើយយើងស្តាប់គេទៅ គេបំបែកម៉ោយើងដូចយល់គេស្រាយសំរាយអោយយើងដឹង។
កះ ចុះអ៊ុំមានចាំចម្រៀងណាដែរអ៊ុំចាំតាំងពីក្មេងដល់ពេលនេះ.?
ខះ និងហើយចម្រៀងអ៊ុំអត់សូវចាំប៉ុន្មានទេ ច្រៀងអីអ៊ុក៏មិនសូវអ្នកច្រៀងដែរ
និងហើយគ្រាន់តែបានតែស្តាប់ប្លឹ។
កះ អត់អីទេអ៊ុ សំណួរខ្លះវាពិបាកគ្រាន់តាយើងត្រូវតែសួរដោយខប់ចឹងណាអ៊ុំ។
ខះ និងហើយ ទៅតាមបែបបទគេដាក់អោយ។
កះ បែបបទគេដាក់អោយ យើងដឹងថាពេលខ្លះ
ធម្មាពីក្មេងដល់ធំវាផ្លាស់ប្តូរយើងចាស់ហើយចឹង។
ខះ គ្រាន់តាចាស់ទៅខ្ញុំចូលចិត្តស្តាប់បទចម្រៀងតាំងពីក្មេងមករហូតដើល់ចាស់
ខ្ញុំតែងតាមានវិទ្យុ វិទ្យុពីដើមប៉ាខ្ញុំគាត់មានវិទ្យុ
ពេលគាត់ទៅបាត់ខ្ញុំលួចបើកហើយ លួចបើកស្តាប់
ដល់ពេលគាគាត់មកបិទហើយខ្លាចគាត់ដេ។
កះ ហិហិហិ!
ខះ និងហើយដូរយកអាគិចម្តង គេហៅម៉ាកស៊ីលេចបស់ហូឡង់អីនោះពីដើម
ដល់ក្រោយៗម៉ោវាមានអាថ្មពាក់ខ្ញុំទិញប្រើខ្លួនឯង។
កះ ដូររហូត ចុះនៅក្នុងក្រុមគ្រួសារអ៊ុំមានពីណាចេះលេងភ្លេងអត់អ៊ុ?
ខះ អត់មានទេ។
កះ អត់មានទេហរអ៊ុ?
ខះ កូនដូចជាអត់ទេចៅសព្វថ្ងៃដូចជាមាន២នាក់គេទិញគីតាកេះ
កូនពៅខ្ញុំមួយហើយនិងអាកូនទី៣ដូចជាទី៣ និងកូនទី៣។
កះ អូ ចេះកេះគីតា ចា។
ខះ ពីដើមអត់មានភ្លើងដាក់ទេ មានតាថ្ម។
កះថ្មពិលនិងហីអ៊ុ ។
ខះ វិទ្យុមួយនិង កាលមុនប៉ាខ្ញុំដូចជាប្រើថ្ម៥២ដុំម្តង។

កះ អឺម ៥២ដុំហិហិ.។
ខះ យាយទៅវាអត់ជឿ ធំប៉ាប៉ុននេះ អ្នកស្រុកកាលនោះអត់ពីណាមានវិទ្យុទេ
ដល់ពេលល្ងាចឡើងមកហើយ ស្តាប់ល្ខោនចាបុីអីទៅឡើងពេញផ្ទះ។
កះ ជំនាន់១ទៀតដល់វគ្គទូរទស្សន៍ ទូរទស្សន៍ម៉ាសារទៀត។
ខះ ទូរទស្សន៍មានទូរទស្សន៍មើលនិងគេដែរទៅ ទម្រាំវាក៍ឃូរដែរ
ដែរថាក្រុមគ្រួដារយើងវាក្រណាកូន។
កះ និយាយទូវានៅតាមជនបទផង។
ខះ និងហើយ និងហើយ អត់ទេ
ពេលដែរមានទូរទស្សន៍ចូលមកនៅផ្ទះដែរកូនឯងចំណាំម៉ោនិងអែង។
កះ ហិហិ..!
ខះ បើនិយាយពីវិទ្យុ ពួកខ្ញុំមិនសូវអត់ទេ ក្រោយមកទៀតពុកខ្ញុំមានវិទ្យុ
លក់អានោះចេញវាថ្មជ្រើនពេក ទិញអាថ្ម៥ដុំវិញ។
កះ ដូរ!
ខះ និងហើយ !
កះ ចុះអើរ ចុះផ្ទះអ៊ុំមានលក្ខណយ៉ាងណាដែរតាំងពីក្មេងម៉ោដល់ឥឡូវ
ចង់វគ្គសំណួរនិងដែរ ហិហិ។
ខះ តាំងពីក្មេងម៉ោបើនិយាយទៅ
ផ្ទះសំបែងអីក៍វាមិនសូវជាធំហើយវាក៍មិនសូវជាតូចអីទេ ប៉ាម៉ែខ្ញុំគាត់នៅ
ខ្ញុំធំដឹងក្តីឡើង ខ្ញុំឃើញគាត់មានផ្ទះក្បឿង១ ផ្ទះអីនៅសមរម្យហេណាស់ ។
កះ ចាស!
ខះ ហើយមកដល់ខ្ញុំទៀតក្តី ក៍ខ្ញុំអត់ដែរបានធ្វើផ្ទះស្បោផ្ទះអីនៅទេ
ពេលណាខ្ញុំធ្វើផ្ទះ ពីប៉ាម៉ែខ្ញុំគាត់ជួយជាលុយជាអីទៅក៍ធ្វើផ្ទះធ្វើអីទៅបាន២ខ្នង
២ខ្នងនៅដួចផ្ទះនេះសព្វថ្ងៃនេះអែង។
កះ ចា ចុះអ៊ុំផ្ទះដែរ ចុះផ្ទះរបស់អ៊ុំ
អីតើអ៊ុំបានសាងសង់ឬក៍បានជួយសាងសង់ផ្ទះនិងឬអត់ទេ អាផ្ទះ។
ខះ បានធ្វើកូន..!
កះ អ៊ុំអ្នកធ្វើខ្លួនអែងហរអ៊ុំ?
ខះ កាលនោះប៉ាខ្ញុំគាត់នៅ គាត់ជួយធ្វើជាងធ្វើអីៗ ទិញដូរអីយើងទិញទៅ។
កះ យើងអ្នកជួយទិញ ហើយជួយមើលធ្វើ។
ខះ ចាជួយទិញ ជួយរកបងប្អូននៅស្រុកគេម៉ោជួយលើក១ថ្ងៃរួច
រ៉ៃប៉ុងប៉ងទៅក៍បានផ្ទះនិងនៅទៅក៍ប៉ាខ្ញុំគាត់ធ្វើបង្ហើយផ្ទះបាយផ្ទះអីអោយកូន
។
កះ និងអឺ នេះគេសួរមួយទៀត
តើអ៊ុំបានប្រើប្រាស់សំភារៈអ្វីខ្លះសម្រាប់សាងសង់ផ្ទះមួយនេះ មួយនិង ហិហិ។
ខះ ហិហិ ពីឈើទេកូនផ្ទះនិង..!
កះ និងហើយ ហិហិ..!
ខះ មិនមែនផ្ទះថ្មទេ ទើបដែរខ្ញុំនេះទៅខ្ញុំបានលុយពីកូនពីអីទៅខ្ញុំសន្សំ
កូនជួយខ្លះអីខ្លះ សូចផ្ទះនិងឡើងបានរៀបថ្មពីក្រោមនិងហាស។
កះ ជាតនិង!
ខះ បើពីមុនវិញឈើ សសរឈើទាំងអស់។
កះ និងហើយឈើ។
ខះ និង !
កះ អឺ តើមាននរណាគេដែរបង្រៀនអ៊ុំអោយចេះសង់ផ្ទះនិង?
ខះ និយាយទៅវាតជំនាន់ពីចាស់ឪពុកម្តាយ។
កះ និងហើយ ។
ខះ យើងគ្រាន់តាបាន ទិញឈើទិញអីប៉ុននឹង
តែផ្ទះហាសខ្ញុំហាសល្អមៗដែរយើងអត់មានគ្រួសារអត់មានប្តីប៉ុននេះ

អត់មានផ្ទះជំអោយគាត់នៅទេ
ប៉ុន្តែបើល្មមៗខ្ញុំអាចដូចរនាបដូចអីខ្ញុំវាយធ្វើបានខ្លួនអែង។
កៈ អូ!
ខៈ បើឈើណារឹងខ្ញុំស្វាន ។
កៈ ហិហិ។
ខៈ ចេះធ្វើបាន។
កៈ ចុះអ៊ុំ អ៊ុំចេះធ្វើខ្លះៗដែរណេសអ៊ុំ ទាក់ទងនិងដំរនាប ជញ្ជំងអី?
ខៈ ចេះជួយដំ និងហើយបាន។
កៈ ចាស!
ខៈ ក្រាន់តាយើងវាមិនបានស្អាត់ដូចគេ ក្រាន់តាបានជិតៗ។
កៈ ហិហិ ចា!
ខៈ កុំអោយខ្យល់ចូល។
កៈ តើអ៊ុំមានជំនាញអីខ្លះដែរបន្តរវេនក្នុងក្រុមគ្រួសាររបស់អ៊ុំ
ដូចជាឪពុកម្តាយរបស់អ៊ុំឬក៏ពីអ៊ុំទៅកាន់កូនចៅអ៊ុំ?
ខៈ រាល់ថ្ងៃបើបន្តរវេនពីឪពុកម្តាយម៉ោខ្ញុំអ្វើស្រែធ្វើអីនិងអែង។
កៈ ចាស!
ខៈ ពេលដល់ខ្ញុំបានប្តីចញ្ចឹមកូនមកនៅខេត្តនេះខ្ញុំលក់នំបញ្ចកនំអីនិងអែង
ចញ្ចឹមកូនរៀន។
កៈ ចឹងអឺ កូនអ៊ុំចេះធ្វើអានុងដែរ?
ខៈ រាល់ថ្ងៃគេអត់ចេះធ្វើទេ នំបញ្ចកនំអីគេលែងធ្វើអស់ហើយ។
កៈ ហិហិ..!
ខៈ គេរស់ដូចថាខ្ញុំបណ្តុំពួកគេ អាប្រុសៗអោយទៅរៀនទៅបានធ្វើការធ្វើអីទៅ
ស្រីៗបង្រៀនអោយគេទៅរៀនដេររៀនអីទៅ ។
កៈ អូ !
ខៈ រាល់ថ្ងៃគេបើកហាងកាត់ដេរកាត់អីខ្លួនគេទៅណាស់
បើពេលខ្ញុំនៅខ្ញុំធ្វើស្រែធ្វើអី បិទស្រាចិញ្ចឹមជ្រូក ដើម្បីចិញ្ចឹមកូនរៀននិងអែង។
កៈ និងហើយ ចុះអឺ សំនួរជិតអស់ហើយ ហិហិ តើអ៊ុំជួយប្រាប់យើងខ្លះៗអំពី
តើជីវិតអ៊ុំមានជួបការលំបាកអីគេ អ្វីខ្លះក្នុងជីវិញ
ហើយអ៊ុំឆ្លងកាត់វាបានដោយរបៀបណាឬក៏យ៉ាងម៉េចអីចឹង?
ខៈ អានិងគឺ បើជីវិតលំបាកវាឆ្លងកាត់
ជំនាន់លន់នល់មួយឆ្លងកាត់ក្រាប់ស្នីៗក្រាប់បែកក្រាប់អីក្រាប់បាញ់ក្រាប់បោះរប
ស់វានិង ។
កៈ ហិហិ!
ខៈ ដូចថាភ័យក៏ភ័យ រស់ឆ្លងផុតអស់ហើយ។
កៈ ហិហិ!
ខៈ ហិហិ ជួនកាលក្រាប់ផឹងមករត់រត់ចោលកូនមកដល់មាត់ទ្វារ
អឺកូនត្រឡប់ទៅវិញ
កៈ ហិហិ!
ខៈ ឡប់ទៅវិញលើកកូនអូស ជួនកាលអាណាធំៗហៅមូលកូនអោយងើប
ក្រាប់ម៉ោហើយកូន ហើយមាននោះអាបេ
កាលនោះអាមេវាទំលាក់ហាសយប់ប្រហែលម៉ោ៨៨ ។
កៈ ចា!
ខៈ វាទំលាក់ដូចជា៦ក្រាប់ ៦ក្រាប់ហើយវាទៅបាត់
អានុងគេហៅអាយន្តហោះរ៉ែឈ្លបទេ មិនមែនអាបេទេ
បើអាបេវាទំលាក់ដូចជា៣យន្តហោះ ៣យន្តហោះនិងបើខ្ញុំថា
យប់និងដែរទាលាក់ហើយខ្ញុំថា ខ្ញុំគិតថាបើសិនជាអាបេខ្ញុំត្រូវស្លាប់ហើយ
ប៉ុន្តែអា៦ក្រាប់និងវាទៅដាក់តា៦ក្រាប់ហើយក៏វាចេញទៅបាត់ទៅ

ប៉ុន្តែយើងកំពុងតាដេកលក់
កំពុងតាដេកលក់ឃើញលឺសូរយន្តហោះសន្ធឹកខ្លាមងហាស់
បេលដែរវាឡើងទៅវិញវាទំលាក់រួចហើយហាស់។
ក: និង !
ខ: ដល់ពេលខ្ញុំលឺសូរសន្ធឹកយន្តហោះ
ខ្ញុំថាហរអាបេចាក់ហើយយប់នេះប្រហែលជាអត់រស់ទេមើលទៅ ដល់ពេលរួចទៅ
និយាយពីក្បឿង ដែរវាផ្តរនិងគ្រាប់ វាធ្លាក់មកត្រូវយើង។
ក: ត្រូវអានេះវាគ្រាំ ហិហិ។
ខ: ដល់ពេលមុងធ្លាក់ហើយបានមួយសន្ទុះ ប៉ុនកូនអែងសួរបានតាត់រត់ម៉ោមើល
ហៅសួរខ្ញុំថាម៉េចហើយ? ខ្ញុំថាអត់អីទេ ប៉ុន្តែក្តារដែរដេកក្បែរខ្លួនយើងរបើក
ក្តាររនាបហាស។
ក: អូ សាហារវា វាខ្លរ។
ខ: និងហើយវារបើកចេញម៉ោ និងហើយដូចវាខ្លរ ។
ក: ហិហិ គួរអោយខ្លាច ។
ខ: គ្រាប់នេះនៅប្រហែលជាពី៤,៥ម៉ែត្រពីផ្ទះទេកូន។
ក: ហិហិ!
ខ: អត់ឆ្ងាយទេ។
ក: ចឹងបានខ្លរខ្លាំម៉េស។
ខ: ក្លាយជាស្រះគ្រាប់និងហាស ។
ក: អូ គ្រាន់តាគ្រាប់ក្លាយជាស្រះនសអ៊ុ ។
ខ: គ្រាប់វានិងហាស ថាបារអាច់ដីក្លាយជាស្រះ អ៊ុអត់ភរកូនអែងទេ។
ក: ដឹងវាទំងន់ប៉ុនណាទេណ៎អ៊ុ។
ខ: និងហើយ ដឹងគ្រាប់គេប៉ុនណា។
ក: ម៉ានគោនទៅបានចេញជាស្រះ.?
ខ: ផ្ទះអ្នកអៀនប៉ាន់ហាសរបើកដំបូលមកនៅដីអស់។
ក: អូ ហិហិ។
ខ: ផ្ទះគរនៅម្ខាងផ្លរ ផ្ទះអាដែរ គ្រាប់ដាក់និង ដាក់មកខាងផ្ទះខ្ញុំ។
ក: អូ ហិហិ ។
ខ: ទៅអាដែរ គ្រាប់មួយទៀតដាក់អាដែរជិត ជិតផ្ទះអៀនប៉ាន់និងដែរ
ដូចស្រដៀងៗគ្នា វាទំលាក់ដូចមុំចង្រ្កានចឹងអែងកូន គ្រាប់បែកវាធ្លាក់ម៉ោ
ប៉ុនរណ្តៅ សព្វថ្ងៃប្រហែលជាគេលុបហើយ គេលុបធ្វើផ្ទះធ្វើអី គេទិញដីនុង
ប៉ុន្តែបើពីសម័យបុលពតអីនៅទេ កាលចប់ហើយខ្ញុំទៅលេងស្រុក
លេងអីឃើញនៅ ប៉ុន្តែឥឡូវគេលុបអស់ហើយ គេទិញដីនិងអែងធ្វើផ្ទះធ្វើអី
ចឹងបានខ្ញុំថា សម័យនោះវាទំលាក់នៅជិតវត្តតាប៉ោងនិងអែង
ចូលវត្តនិង១គ្រាប់។
ក: កាលនិងដូចជាលីគេធ្វើត្រង់សេសឬក៏ម៉េច?
ខ: និងហើយ ធ្វើត្រង់សេ តែយប់និងចែដន្យហាខ្ញុំ យប់និងវារៀងរលីមស្រីចៗ។
ក: អូ!
ខ: វាអត់មានក្មេងរត់លេង ថ្ងៃនិងខ្ញុំថាបើមានក្មេងរត់លេងដូចតារាល់ថ្ងៃ
ខ្ញុំថាងាប់ មានងាខ្លះ ឬបើមិននេះការបួសខ្លះដែរ
ព្រោះក្មេងវារត់លេងតាមថ្នល់និងអែង
អាគ្រាប់បែកនិងនៅប្រហែលជាមាត់ទ្វានិងអែង រណ្តៅគ្រាប់និងហាស់។
ក: អូ !
ខ: ម៉ោអាដែរផ្លរក្មេងរត់លេង ក្មេងប៉ុនៗនេះអែងរត់លេង។
ក: ចុះថ្ងៃដែរទំលាក់និងហើយ ម៉េចវិញទៅអ៊ុ វាលែងអីឬក៏ម៉េច?
ខ: វាអត់អីទេវាឈប់ទំលាក់វិញ។
ក: អូ វាឈប់ទំលាក់តាំងពីនិងម៉ោរហូតទៅ?

ខ៖ មែនរហូតទេ វាទៅទំលាក់នៅណាទៀតមិនដឹងទេ
តែភូមិនិងវាឈប់ទំលាក់ហើយ។
ក៖ និយាយរួមវាទំលាក់គ្រប់ភូមិមែនអ៊ុ?
ខ៖ វាទំលាក់ភូមិណា អោយតាគេអោយការណ៍អោយវា វាទំលាក់ហើយ
និយាយថាដូចមានខ្ទែរក្រហមមានអីនិងណា វាដូចជំនាន់លន់នល់អីនិងហារ។
ក៖ ជំនាន់លន់នល់ហើយបានមកប៉ុលពត។
ខ៖ និងហើយជំនាន់លន់នល់និងអែង
ទំលាក់ហើយតិចក៏ជាខ្ញុំរត់ម៉ោសួរប៉េចហើយកូន?
ជាំខ្ញុំរាងនៅឆ្ងាយប្រហែលជាពីនេះទៅ ហី
យើងថាប្រហែលពីនេះទៅមាត់ផ្លូវចេញទៅផ្តល់ចុះ រត់មកសួរមើលកូន
ពេលក្រោយមកទៀត អត់ពីត្រួសារទៅខ្ញុំពិបាកដែលមិនមែស្រួលទេកូន
ជីវិតដែលយើងអត់មានបង្គោលត្រួសារដើម្បីរឹងមាំ។
ក៖ ចាសនិងហើយ។
ខ៖ អត់អ្នកចិញ្ចឹមពួកយើង។
ក៖ ធម្មតាយើងមើលកូនផង រកលុយរកអី។
ខ៖ មើលកូនផង ការងារប្រុសការងារស្រីនៅលើយើងទាំងអស់។
ក៖ និងហើយ!
ខ៖ ប៉ុន្តែក៏ចេះតែស៊ូទ្រាំដែល ចេះបានតាខ្ញុំគិថា មិនមែនថានេះទេ ខ្ញុំគិតថា
អ្វីដែលយើងធ្វើគឺព្រះអ្នករៀបចំអោយយើងបានមកជួប
ខ្ញុំបើនៅអីស្រែប្រហែលខ្ញុំដាប់ ខ្ញុំស្លាប់ដោយសារខ្ញុំមានជំងឺបេះដូងនិងហាស។
ក៖ ចុះឥឡូវម៉េចហើយអ៊ុំអាជំងឺនិង?
ខ៖ វាថប់ ជំងឺនិងសព្វថ្ងៃខ្ញុំប្រើថ្នាំជាប្រចាំទៅវាអត់អីទេ
ប៉ុន្តែមួយរយៈនោះដែលខ្ញុំនៅអីលើ ត្រូវកោសខ្យល់មួយថ្ងៃបើមិនពីរដងក៏ម្តង។
ក៖ កោសទៅវាជូរមែនអ៊ុ?
ខ៖ កោសទៅវាដូចបាត់ថប់បាត់អី អ្នកណាឡើងផ្ទះខ្ញុំ
ខ្ញុំហៅគេអោយកោសខ្យល់អោយខ្ញុំសិន បានខ្ញុំអោយគេទៅ។
ក៖ ហិហិ បានអោយគេទៅវិញ។
ខ៖ និងហើយ ព្រោះគេម៉ោ គេមករកស្លែរ រកប្រហុក រកស្ករ។
ក៖ គេទិញក៏គេសុំអ៊ុ?
ខ៖ គេទិញ មិនមែនមកសុំទេ ក៏ប៉ុន្តែ។
ក៖ ហិហិ យើងលក់។
ខ៖ ខ្ញុំលក់ថា ហើយកោសខ្យល់អោយខ្ញុំសិនមកបានទៅវាល់ស្លែរកើត
រួចទៅខ្ញុំទៅវាល់ស្លែរហើយវាល់អោយគេលើសទៅ
គេកោសខ្យល់អោយយើងហើយនោះ។
ក៖ និងហើយអ៊ុ !
ខ៖ បើថាទិញប្រហុកក៏អោយគេលើសប្រហុក ជួកកាលខ្ញុំអោយកន្លះគីឡូ
ទិញមួយគីឡូក៏អោយមួយគីឡូកន្លះអីទៅ ស្ករអីក៏ចឹងដែល។
ក៖ និង!
ខ៖ ថ្ងៃក្រោយគេមករកយើងក៏ប្រើគេទៀតទៅ ធ្វើអីៗជួយ។
ក៖ ចុះអ៊ុំ និងហើយអ៊ុ ចុះអ៊ុំមានបទពិសោធន៍ល្អៗអ្វីខ្លះក្នុងជីវិតអ៊ុ
ដូចជាអាពាពិពាហ៍កូនចៅ ឬក៏អីផ្សេងៗទៀត?
ខ៖ និង ខ្ញុំបើអាពាពិពាហ៍ដូចខ្ញុំផុតហើយ
ខ្ញុំដូចអត់បានធ្វើអីអោយខុសពីសិលធម៍របស់ព្រះ
យើងត្រូវគោរពច្បាប់ព្រហ្មចារីភាពអីហាស
គឺខ្ញុំអត់ដែលខិលខូចឬមានស្នេហាអីនិង អត់បេះមានដូចគេទេកូន។
ក៖ វាដូចជាអ្វីដែរល្អៗក្នុងជីវិតរបស់អ៊ុំ។

ខ៖
មិនដែលប្រព្រឹត្តិអីដែលខុសច្បាប់ព្រហ្មចារីភាពមុនពេលរៀបអាពាហ៍ពិពាហ៍អី
ខ្ញុំអត់មានទេ។
ក៖ ចា!
ខ៖ ហើយខ្ញុំដល់បានប្តីបានអីមកទៀតខ្ញុំក៏មិនដែល
មិនដែលអ្វីអីអោយគេពិបាក ព្រោះខ្ញុំពេលបានប្តីដឹងតែខំរកស៊ី
ប្តីគាត់ក៏អត់ចេះធីកអត់ចេះអីដែល តែក្រុមគ្រួសារគាត់ដូចថា
បើនិយាយទៅពួកក្រុមគ្រួសារគាត់
បើនិយាយពីឪពុកម្តាយខ្ញុំគាត់អត់មានដីស្រែដីអីទេ
ទើបនិងឥឡូវទេដែលវាក្រឡាប់ចាក់សង្គមទៅវា គេចែកដីរបបហាស
បានគាត់មានថា។
ក៖ ដីរបបគេប៉ុលពតហើយហីគេចែករបបនិង។
ខ៖ អត់ទេ។
ក៖ មុន?
ខ៖ ចប់ប៉ុលពត។
ក៖ ចប់ប៉ុលពត?
ខ៖ ដីគេរួម រំលាយចែកគ្នា បើពីមុនប៉ុលពតដីអត់ទាន់ចែកគ្នាទេ
ដល់ពេលរួចទៅក៏ម៉ែប៉ាខ្ញុំគាត់ឃើញក្រុមគ្រួសារវា គេរកស៊ីតែនិងកម្លាំងហាស
គាត់កាប់ជ្រូក គាត់បង់ត្រីចិញ្ចឹមកូន គាត់ក៏អោយកូនគាត់ទៅនៅភ្នំពេញអីទៅ
បងប្រុសមួយប្តីខ្ញុំមួយទៅនៅភ្នំពេញរកស៊ី រត់តុគុយទាវ លក់នំបុ័ង
ដល់ក្រោយមកគាត់ឈប់ស៊ីឈ្នួលគេរត់តុគុយទាវ ទៅលក់នំបុ័ង
លក់នំបុ័ងអីទៅគាត់ក៏សល់លុយសល់អីធ្វើមាសធ្វើអីសល់លុយការប្រពន្ធការអីនិ
ងហាសខ្លួនគាត់ ដល់ពេលរួចទៅបានប្រពន្ធបានអីទៅ
គាត់ក៏មិនដែលធ្វើអោយយើងពិបាកដែល
គាត់មិនចេះធីកមិនចេះស៊ីមានស្រីអីទេដឹងតែខំរក
តែដល់ពេលយើងបែកគ្នាស្លាប់បាត់ទៅនិងក៏ចប់សព្វគ្រប់។
ក៖ និងហើយអ៊ុ ចុះតាំងពីក្មេងអ៊ុសឆ្នឹមចង់ធ្វើអីពេលធំឡើង?
ខ៖ អ៊ុពីក្មេងពីអីដូចមិនបានស្រមៃចង់ធ្វើអីទេ គ្រាន់សង្ឃឹមថា
ពីដើមេប៉ាខ្ញុំគាត់តែងទៅភ្នំពេញត្រឡប់មកវិញគាត់តែងនិយាយហាស
គាត់និយាយថាគាត់ទៅរាំងទៅអីសប្បាយហាស ចិត្តនោះស្រមៃហាសស្រមៃ
គិតទៅមនុស្សសេចក្តីស្រមៃនិងការប៉ងប្រាថ្នាបាន ខ្ចាំហាស
អ្នកណាទៀតមិនដឹងទេតែខ្ញុំបានសម្រេច
ខ្ញុំស្រមៃហែបើបានទៅភ្នំពេញហើយជួនកាលគាតើទៅសៀមរាបគាំគាត់ត្រឡប់ម
កវិញគាត់និយាយ
សៀមរាបប្រាសាទអង្គរល្អណាស់កូនអើយមិនដឹងជាធ្វើរបៀបម៉េច
ទៅចិត្តនិងក៏ប្រាថ្នាចង់ចង់ស្គាល់សៀមរាប
តែសព្វថ្ងៃនេះចឹងបានខ្ញុំថាសេចក្តីស្រមៃនិងការប៉ងប្រាថ្នានិងបាន ។
ក៖ ហិហិ អាឡូវបានស្គាល់ទាំងក្រៅប្រទេសទៀត
ពួកខ្ញុំមិនទាន់ស្គាល់ក្រៅប្រទេសផង។
ខ៖ ហិហិ បានទៅនៅភ្នំពេញបានទៅមុខវាំង បានដឹងអីស្គាល់អស់ហើយ
ហើយសៀមរាបសឹងថាទៅកំវាឆ្អែតឆ្អន់ដែលហើយ ហូននៅនិងបី។
ក៖ អូ!
ខ៖ សុទ្ធតាប្រុសៗនៅសៀមរាបនិង។
ក៖ និង ។
ខ៖ ហើយមួយទៀត និយាយពីអាសេចក្តីស្រមៃរបស់ខ្ញុំវែងឆ្ងាយ
ស្រមៃចង់មកនៅស្រុកផ្សារ ដូចថារៀបចំមកនៅក៏បាន

ដល់ពេលមកនៅស្រុកផ្សារហើយក៏រកស៊ីនិងទៅស្រមៃចង់មើលទូរទស្សន៍
ពីដើមអោយតាព្រលប់ៗខ្ញុំចង់មើលរឿងរាមកេរ្តិ៍។
ក៖ អូ រាមកេរ្តិ៍។
ខ៖ ព្រលប់នាំកូនមមើលផ្ទះប្អូន គេមានលុយគេទិញមើលមុនខ្ញុំ
ទៅដល់ពេលក្រោយម៉ោ ខ្ញុំស្រមៃទៅថា
ហូបើបានទូរទស្សន៍ដេកមើលនៅផ្ទះអែងដឹងស្រួលប៉ុនណាទេន៎ ហិហិ
មានត្រៃដេកមានទូរទស្សន៍ខ្លួនអែងមើលដូចស្រួល
ពេលក្រោយមកកូនផងខ្ញុំផង លក់ជ្រូកលក់អីផ្សំគ្នាទិញទូរទស្សន៍
បើនិយាយមកសព្វថ្ងៃខ្ញុំអត់ហ៊ាននិយាយទេនែក។
ក៖ សន្សំទម្រាំបាន។
ខ៖ ទិញទូរទស្សន៍កាលនិង៥២០ បើគិតជាមាមិនដឹងម៉ានទេ.
ក៖ ហិហិ ថ្លៃ.
ខ៖ ថ្លៃណាស់លុយកាលនិង កាលនិងដូចសម័យអ៊ុនតាក់។
ក៖ ប្រើភ្លើងហ៎អ៊ុ?
ខ៖ នឹងហើយប្រើភ្លើង។
ក៖ កាលនិងភ្លើងរដ្ឋហ៎?
ខ៖ កាលនិងកូនខ្ញុំបានប្តី នឹងហើយកូនខ្ញុំបានប្តី
កូនប្រសារខ្ញុំវាអត់ចេះនៅឯងឯីត ទៅវារភ្លើងតអីអោយ។
ក៖ អូ!
ខ៖ ដល់ពេលរួចទៅក៏ទិញទូរទស្សន៍និងដាក់ផ្ទះមួយអា២១អ៊ីញអាធំដែរ
បានទូរទស្សន៍និងដេកមើល ស្រមៃចង់ជិះម៉ូតូបានទូរទស្សន៍ហើយ
បានទូរទស្សន៍មើលហើយ ចងបានម៉ូតូគ្រាកូនដូបទៅណាទៅណី
ពេលក្រោយមកកូនខ្ញុំអាទី២បានធ្វើការអោយស៊ីម៉ាក់
បានប្រាក់ខែស៊ីម៉ាក់ដោះមីន និងហើយ
បានប្រាក់ខែនឹងផ្សំម៉ោទិញម៉ូតូនិងដូជា១៤០០ជាង។
ក៖ អូ។
ខ៖ ថ្មី បានម៉ូតូនិងជិះហើយស្រមៃចង់ជិះឡានទៀត ហិហិ។
ក៖ ហាហា ស្រមៃរហូត។
ខ៖ ហិហិ ស្រមៃតរហូត ចឹងបានខ្ញុំថា ។
ក៖ ស្រមៃមួយបានហើយស្រមៃចង់បានមួយទៀត ហិហិ ចង់បានរហូត ហាហា។
ខ៖ នឹងហើយ ស្រមៃចង់ជិះឡាន
ដល់ពេលក្រោយម៉ោកូនទៅនៅសៀមរាបហើយទៅវាក៏បានទិញឡានទិញអីបាន
ជិះដឹកជញ្ជូនយើងស្រួល លែងជិះរថយន្តឈ្នួលហើយ
ដល់ពេលរួចទៅស្រមៃចង់ជិះយន្តហោះ ហិហិ។
ក៖ ហាហា បានជិះមែន។
ខ៖ បានជិះមែន ហិហិ កាលនិងអរគុណព្រះអង្គ បានទៅហ្វីលីពីន។
ក៖ នឹងហើយ។
ខ៖ មុនគេ នឹងបានជិះយន្តហោះដំបូង.។
ក៖ ជានៅដំបូងគេទៀត។
ខ៖ នឹងហើយ ។
ក៖ ពួកខ្ញុំប៉ុននេះហើយនៅមិនទាន់ស្គាល់អីនៅឡើយ។
ខ៖ នឹងហើយ ដល់ក្រោយៗមកទៀតខ្ញុំបានទៅសិង្ហបុរី ខ្ញុំទៅឌូប៉ៃ។
ក៖ ទៅឌូប៉ៃទៀតអ៊ុ?
ខ៖ នឹងហើយ ។
ក៖ អូ សាហារ។
ខ៖ ទៅតាមធ្លារ។
ក៖ តាមធ្លារៗក៏។

ខ៖ ទៅថៃទៅអីៗខ្ញុំបានទៅញឹកញាប់ដែល ប៉ុនតែអត់ទាន់បានទៅបាងកក់ទេ
ក្រាន់បានទៅសួនលួង ទៅសុវត្ថិលើយទៅអី
ចេះតាដើរលេងទៅសុរិនអីនិងហើយ។
ក៖ ឌូប៉ៃ សូម្បីស្រមៃក៏ពីបាកទៅដែល ហិហិ បើថ្លៃដែរ គោះបីធ្វរក៏ថ្លៃដែរ។
ខ៖ ១៣០០។
ក៖ និងហើយច្រើនដែល។
ខ៖ និងហើយ កូនអោយលុយខ្លះ លុយខ្លួនអែងផ្សំខ្លះ ទៅក៏ទៅ បានទៅឌូប៉ៃ
ហើយបានទៅហុងកុងទៀត ។
ក៖ តិចទៀតបានទៅហុងកុងមួយទៀត និងហើយ។
ខ៖
ប៉ុន្តែនៅជប៉ុនមួយទៀតចង់ទៅដែលចាំមើលគេរៀបចំចាំមើលតាមយន្តហោះគេ
បញ្ជាតម្លៃហាស់។
ក៖ បា នៅតាមយន្តហោះ បើយតាមវិហារដូចជាអត់មានទៅជប៉ុនទេ
ទាល់តាទៅខ្លួនអែង។
ខ៖ អត់មានទាល់តារៀបចំទៅខ្លួនអែង។
ក៖ និងហើយទាល់តាទៅខ្លួនអែង ព្រះវិហារបរិសុទ្ធមាន
តែទាល់តាទៅខ្លួនអែងដែរ។
ខ៖ និងគេរៀបចំ ថ្លៃហាស់ អ៊ុនៅវិហារនិងតាត់ទៅ អស់ជិះ១០០០០ហាស់
ប៉ុនគ្នាដូចជា៤នាក់ ខ្ញុំធ្លាប់ស្គាល់អ៊ែលឌើរម្នាក់តាត់ដូចជាចេះជប៉ុន
ចេះច្រើនព្រោះតាត់ធ្លាប់ទៅនៅជប៉ុន។
ខ៖ និងហើយ!
ក៖ អ៊ែលឌើរAPឥឡូវនិង អ៊ែលឌើរវិទ្ធ ។
ខ៖ ដល់ឥឡូវ មិនដឹងបានទៅឬអត់ទេ ចេះតាស្រមៃៗទៅ។
ក៖ ហិហិ ក្រែងបានទៅមែន និងហើយអ៊ុ
បើសិនអ៊ុចង់ផ្តាំប្រាប់អ្វីមួយទៅកាន់កូនចៅជំនាន់ក្រោយ តើអ៊ុនិងប្រាប់អ្វីខ្លះ?
ខ៖ ហឹម ដឹងប្រាប់ថាអីទេ និងហើយកូនចៅជំនាន់ក្រោយ
ប្រាប់ពូកគេទាំងអស់គ្នាអោយគេដើរតាមផ្លូវត្រឹមត្រូវទាំងអស់គ្នារបស់ព្រះជាម្ចា
ស់ទៅ។
ក៖ និងហើយ!
ខ៖ វានិងមានសុភមង្គល។
ក៖ ចា!
ខ៖ ហើយសុភមង្គលក៏មានលើផែនដីនេះយ៉ាងច្បាស់
ហើយជីវិតដ៏អស់កល្បជានិច្ចនិងមាននៅផែនដីថ្មីទៀត។
ក៖ និងហើយអ៊ុ អរគុណច្រើន ដោយសារសំនួរសំភាសន៍យើងអស់ហើយ ប៉ុន្តែ។
ខ៖ ចាស។
ក៖ ខ្ញុំសុំសួរមួយទៀតនិងសុំថតរូបជាមួយអ៊ុ ហើយមួយទៀតអី សួរអ៊ុសំណួរដូចជា
តើអ៊ុអនុញ្ញាតិដើម្បីដូចជាអោយពូកខ្ញុំ
ដូចជាដាក់ឡើបសំលេងនិងហើយនិងរូបថតនិងទៅលើគេហទំព័រសកលវិទ្យាល័យ
ព្រឹកហាំយ៉ងបានដែរឬទេ?
ខ៖ បានកូន បានកូន។
ក៖ សកលវិទ្យាល័យមួយនិងនិង ។
ខ៖ ចាសស្គាល់ ព្រឹកហាំយ៉ង។
ក៖ ចាស ព្រឹកហាំយ៉ង ព្យាការីបន្ទាប់ពីយ៉ូសែបស្ម៊ិធ។
ខ៖ និងហើយ។
ក៖ និងហើយ ពូកខ្ញុំធ្វើមួយនិងទាក់ទងនិងសកលវិទ្យាល័យមួយនិង
ថតធ្វើហើយយើងយកទៅអោយអ្នកកាន់មួយនិង
គាត់និងបញ្ជូនទៅសកលវិទ្យាល័យមួយនិងចឹងហាស់

តែមុននិងពួកគាត់ជុសមួយនិងលើគេហទំព័ររបស់ពួកគាត់
ពួកគាត់ត្រូវសុំអនុញ្ញាតិពីអ្នកសំភាសន៍មួយនិងសិន។
ខ៖ និងហើយៗត្រូវ។
ក៖ និងហើយ ដូចជាសុំពីម្ចាស់ដើមគេដែល។
ខ៖ និងហើយ
បើមិនមានការអនុញ្ញាតិវាមិនមានការសំភាសន៍ជាពាក្យពេចន៍ចឹង។
ក៖ ចានិង ។
ខ៖ អត់អីទេបានក្លូន។
ក៖ ដូចជា និងហើយ អរគុណច្រើនអ៊ុំ
មួយនិងគេសុំអ៊ុំដូចជាអនុញ្ញាតិក៍បានមិនអីក៍បាន
ក្រាន់តាមួយនិងគេរក្សាទុកអោយយើង សិទ្ធរបស់យើង។
ខ៖ និងហើយ។
ក៖ និងហើយ ចឹងអរគុណច្រើនអ៊ុំ ប៉ុណ្ណឹងអស់ហើយ ហិហិ។
ខ៖ ចា។
ក៖ អរគុណច្រើន រំខានអ៊ុំម៉ោងហូបបាយ១១កន្លះ។
ខ៖ អត់អីទេ។
ក៖ និងអរគុណ។